# សេចក្តីថ្លែងនៃបេក្ខជនព្រឹទ្ធសភាសហរដ្ឋអាមេរិក

ព្រឹទ្ធសភាសហរដ្ឋអាមេរិក៖

- បំរើជាព្រឹទ្ធសភាមួយរូបក្នុងចំណោមព្រឹទ្ធសភាពីររូបដែលតំណាងឱ្យផលប្រយោជន៍រដ្ឋកាលីហ្វ័រញ៉ានៅក្នុងព្រឹទ្ធសភាសហរដ្ឋអាមេរិក។
- ធ្វើញត្តិ និងបោះឆ្នោតលើច្បាប់ជាតិថ្មី។
- បោះឆ្នោតលើការអនុម័តយកចៅក្រមសហព័ន្ធ, ក្រសួងយុទ្ធធម៌តុលាការកំពូលសហរដ្ឋអាមេរិក, និងមុខងារមន្ត្រីស៊ីវិលនិងយោធាថ្នាក់ខ្ពស់នានាដែលចាត់តាំងដោយប្រធានាធិបតី។

---

DIANNE FEINSTEIN
គណៈបក្សអាទិភាព៖
ប្រជាធិបតេយ្យ

1801 Avenue of the Stars, Suite 829
Los Angeles, CA 90067

(310) 203-1012
www.diannefeinstein2012.com

ពេលនេះគឺជាពេលវេលាដ៏លំបាកសំរាប់រដ្ឋនិងជាតិរបស់យើង។ សេដ្ឋកិច្ចរបស់យើង, ខណៈដែលធូរស្រាលឆាប់, គឺកំពុងងើបចេញពីសភាពធ្លាក់ដុនដាបនៃសេដ្ឋកិច្ចដ៏អាក្រក់មួយក្នុងប្រវត្តិសាស្ត្រអាមេរិកាំង។ ប្រទេសយើងប្រឈមមុខនឹងសេដ្ឋកិច្ចដ៏គ្រោះថ្នាក់ និងសន្តិសុខជាតិជួបប្រទះការប្រជែងទូទាំងពិភពលោក។ រដ្ឋកាលីហ្វ័រញ៉ាត្រូវការអ្នកដឹកនាំមានបទពិសោធន៍នៅក្នុងព្រឹទ្ធសភាសហរដ្ឋអាមេរិក ដែលត្រូវរៀបចំដើម្បីជួបនឹងការប្រកួតប្រជែងទាំងនោះ។ អាទិភាពទីមួយរបស់ខ្ញុំគឺនាំយកភាពលំនឹងដល់សេដ្ឋកិច្ចរដ្ឋកាលីហ្វ័រញ៉ានិងជាតិ។ ខ្ញុំគាំទ្រវិធានការដែលមានសុភវិនិច្ឆ័យ ដើម្បីធ្វើឱ្យសេដ្ឋកិច្ចលូតលាស់ ដូចជាការកាត់ពន្ធពីបញ្ជីប្រាក់ខែ, ផែនការឱ្យខ្ចីប្រាក់ជាថ្មីដើម្បីជួយដល់ម្ចាស់ផ្ទះដែលជំពាក់ប្រាក់និក្ខេបរបស់គេ និងបញ្ចប់ការរាលដាលនៃការរឹបអូសយកផ្ទះនៅក្នុងរដ្ឋរបស់យើង, ផែនការហេដ្ឋារចនាសម្ព័ន្ធដែលត្រូវការយ៉ាងខ្លាំងដើម្បីបង្កើតការងារធ្វើ, ធ្វើការគាំទ្រគ្រូបង្រៀននិងប្រាក់ខែរបស់អ្នកឆ្លើយតបទីមួយ, និងផ្តល់ក្រេឌិតពន្ធដារសំរាប់និយោជក ឬហាងពាណិជ្ជកម្ម ដើម្បីជួលអតីតយុទ្ធជនដែលគ្មានការធ្វើ និងអ្នកដែលគ្មានការធ្វើរយៈពេលយូរ។ ខ្ញុំក៏បានប្តេជ្ញាយ៉ាងជ្រាលជ្រៅដើម្បី ការពារសន្តិសុខសង្គម និងកម្មវិធីមេឌីឃែរ ដែលគឺជាកត្តាសំខាន់សំរាប់មនុស្សចាស់ជរារបស់យើង។ គណៈកម្មការស៊ើបការសម្ងាត់ព្រឹទ្ធសភាដែលរូបខ្ញុំជាប្រធាន ឥឡូវនេះគឺប្រតិបត្តិការក្នុងរបៀបគ្មានបក្សព័ន្ធ ការនេះធ្វើឱ្យយើងមានប្រសិទ្ធិភាពខ្លាំងក្នុងការការពារសុវត្ថិភាពរបស់ជាតិ, បង្អាក់ដល់សកម្មភាពភេរវៈជន, និងផ្តល់ការមើលត្រួតត្រាហ្មត់ចត់ដល់ទីភ្នាក់ងារទាំង 16 នៃសហគមន៍ស៊ើបអង្កេត។ ក្នុងនាមជាសមាជិកនៃគណៈកម្មការតុលាការ ខ្ញុំស្ថិតនៅក្នុងភាពប្រុងប្រយ័ត្នជានិច្ចក្នុងការការពារសិទ្ធិពលរដ្ឋដល់ពលរដ្ឋយើងទាំងអស់ ហើយខ្ញុំមិនងាករេក្នុងការការពារសិទ្ធិរបស់ស្ត្រីក្នុងការជ្រើសរើសប្រឆាំងនឹងអំពើប្រើកំលាំងរំលោភបំពាន។ ខ្ញុំឈរឈ្មោះជាព្រឹទ្ធសភាសហរដ្ឋអាមេរិកពីព្រោះខ្ញុំជឿថាខ្ញុំមានជំនាញ មានបទពិសោធន៍, និងប្តេជ្ញាមុះមុតដើម្បីធ្វើរដ្ឋកាលីហ្វ័រនីញ៉ាឱ្យមានការកែប្រែ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្ររបស់លោកអ្នក។

---

ELIZABETH EMKEN
គណៈបក្សអាទិភាព៖
សាធារណរដ្ឋ

P.O. Box 81
Danville, CA 94526

(925) 395-4475
info@emken2012.com
www.emken2012.com

យើងមិនអាចផ្លាស់ប្តូរវ៉ាស៊ីនតោនបានទេដោយគ្មានការផ្លាស់ប្តូរ មនុស្សខ្លះនៅក្នុងវ៉ាស៊ីនតោន។ នយោបាយគាំងស្ទះដែលយើងមើលឃើញរាល់ថ្ងៃគឺកំពុងធ្វើឲ្យមានការឈឺចាប់ដល់អ្នកកាលីហ្វ័រញ៉ា។ ភាពឥតការងរធ្វើនៅក្នុងរដ្ឋរបស់យើងមានកំរិតខ្ពស់ជាងកំរិតមធ្យមថ្នាក់ជាតិ, ការលូតលាស់ការងារមានកំណើនយឺតៗ នេះគឺមានន័យថាបុរស ស្ត្រីជាអ្នកធ្វើការងារខ្លាំងនៅរដ្ឋកាលីហ្វ័រញ៉ាមានឳកាសតិចតួចណាស់សំរាប់រកងារ។ ក្នុងចំណោមទីក្រុង10ក្នុងសហរដ្ឋអាមេរិកដែលមានេសដ្ឋកិច្ចអាក្រក់ខ្លាំងជាងគេ គឺ9 នៅក្នុងរដ្ឋរបស់យើង។ រដ្ឋកាលីហ្វ័រញ៉ាមានតំណាងដដែលៗនៅក្នុងព្រឹទ្ធសភាសហរដ្ឋអាមេរិកជិតម្ភៃឆ្នាំ, តែការប្រណាំងប្រជែងរបស់យើងកាន់តែអាក្រក់ទៅៗ។ ព្រឹទ្ធសភាបរាជ័យក្នុងការធ្វើសកម្មភាពលើសេចក្តីព្រាងច្បាប់សំខាន់ៗ មានន័យថាពាណិជ្ជកម្មខ្នាតតូចដែលយើងត្រូវការសំរាប់បង្កើតការងារត្រូវបានកំរាមកំហែងដោយការយកពន្ធដារខ្ពស់ នឹងបទបញ្ញត្តិមានភាពស្មុគ្រស្មាញច្រើន។ កសិកររបស់យើងនៅ Central Valleyត្រូវការទឹកធ្វើចំការ។ ក្រុមបច្ចេកទេសខ្ពស់របស់យើងត្រូវការកំណែទម្រង់ពន្ធដារដែលជួយរក្សាការងារទុកនៅទីនេះ។ សន្តិសុខជាតិរបស់យើង និងឧស្សាហកម្មការពារកំពុងតែមានការកំរាមកំហែងធ្ងន់ធ្ងរ។ ស្ថានភាពដដែលៗជាក់ស្តែងត្រូវបរាជ័យ។ យើងត្រូវការភាពដឹកនាំថ្មី, បំពេញថាមពលជាថ្មីឡើងវិញ, និងព្រឹទ្ធសភាមួយរូបដែលចាប់ផ្តើមពីថ្មីស្រឡាង។ ក្នុងនាមជាភរិយា និងជាម្តាយនៃកូនបីនាក់ ខ្ញុំមានការបារម្ភសំរាប់អនាគតរបស់កូនខ្ញុំ។ ខ្ញុំបានប្តេជ្ញាធ្វើឱ្យវ៉ាស៊ីនតោនធ្វើការឡើងវិញដោយធ្វើឱ្យងាយស្រួលក្នុងការបង្កើតការងារនៅក្នុងរដ្ឋកាលីហ្វ័រញ៉ាជាជាងនៅប្រទេសក្រៅដោយធានាឱ្យរូបអ្នក និងគ្រួសារអ្នកអាចជ្រើសរើសការអប់រំ និងការថែទាំសុខភាពដែលត្រឹមត្រូវចំពោះអ្នក ហើយដែលធ្វើឱ្យយើងអាចជួយដល់អ្នកដែលត្រូវការពិតប្រាកដ។ ខ្ញុំមានកិត្តិយសនឹងទទួលបានការគាំទ្រពីលោកអ្នក។ ចង់ស្វែងយល់ច្រើនថែមទៀតចូរទៅគេហទំព័រ *www.Emken2012.com.*

---

លំដាប់លេខរៀងនៃសេចក្តីថ្លែងរបស់បេក្ខជនឈរឈ្មោះ គឺត្រូវបានកំណត់ដោយការចាប់ឈ្មោះផ្សងសំណាងយកចេញពីតួអក្សរ ។
សេចក្តីថ្លែង នៅក្នុងទំព័រនេះ គឺត្រូវបានឧបត្ថម្ភដោយបេក្ខជនរៀងខ្លួនៗ ហើយមិនត្រូវបានត្រួតពិនិត្យមើលភាពត្រឹមត្រូវឡើយ។
សេចក្តថ្លែងនិមួយៗត្រូវបានដាក់បញ្ជូនមកដោយស្ម័គ្រចិត្ត ពីបេក្ខជន ហើយត្រូវបានចំណាយថ្លៃបោះពុម្ពដោយខ្លួនគេ។